# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន
លេខ ០១៦ សសរ ព.ម

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតក្រុមការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស របស់ក្រសួងព័ត៌មាន**

**រដ្ឋមន្ត្រីក្រសួងព័ត៌មាន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជានៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាល សោតទស្សន៍ ជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍
- យោងសេចក្តីសម្រេចលេខ ០០៣ សសរ ព.ម ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការប្រគល់ភារកិច្ច និង កំណត់របៀបរបបការងាររបស់ថ្នាក់ដឹកនាំក្រសួងព័ត៌មាន
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្សរបស់ក្រសួងព័ត៌មាន ដែលមានអក្សរហៅកាត់ថា ក.ប.ទ.ជ.ម.ព.ម ដូចមានសមាសភាពខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **សារ៉េន បណ្ឌិត្យ** រដ្ឋលេខាធិការ | | ប្រធាន |
| ២- ឯកឧត្តម **កែវ សុធា** អនុរដ្ឋលេខាធិការ | | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- ឯកឧត្តមអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | | អនុប្រធាន |
| ៤- ឯកឧត្តមអគ្គនាយកព័ត៌មាន និងសោតទស្សន៍ | | អនុប្រធាន |
| ៥- ឯកឧត្តមអគ្គនាយកទូរទស្សន៍ជាតិកម្ពុជា | | អនុប្រធាន |
| ៦- លោកជំទាវអគ្គនាយិកាវិទ្យុជាតិកម្ពុជា | | អនុប្រធាន |
| ៧- លោកជំទាវអគ្គនាយិកាទីភ្នាក់ងារសារព័ត៌មានកម្ពុជា | | អនុប្រធាន |
| ៨- លោកស្រី នង វត្ថា អគ្គនាយិការង ព័ត៌មាននិងសោតទស្សន៍ | | ប្រធានលេខាធិការដ្ឋាន |
| ៩- ប្រធានមន្ទីរព័ត៌មានរាជធានី-ខេត្ត | | សមាជិក។ |

**ប្រការ២.-**

ក.ប.ទ.ជ.ម.ព.ម មានភារកិច្ចដូចតទៅ៖

- លើកគោលនយោបាយ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ក្នុងក្របខណ្ឌក្រសួង
- សម្របសម្រួល ណែនាំ និងបង្កលក្ខណៈក្នុងការអនុវត្តកម្មវិធីបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ទៅតាមអគ្គនាយកដ្ឋានចំណុះក្រសួង ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (មន្ទីរព័ត៌មានរាជធានី ខេត្ត ទូទាំងប្រទេស)
- ស្វែងរកការឧបត្ថម្ភថវិកា និងសម្ភារៈពីគ្រប់មជ្ឈដ្ឋានដើម្បីគាំទ្រដល់ការអនុវត្តផែនការជាតិ ប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស
- ផ្លាស់ប្តូរយោបល់ បទពិសោធន៍ និងសហការជាមួយក្រសួង-ស្ថាប័ននានា អំពីបញ្ហាបង្ការទប់ស្កាត់ លើកកម្ពស់ការយល់ដឹងផលប៉ះពាល់នៃការធ្វើអាជីវកម្មពលកម្ម និងផ្លូវភេទ
- សម្របសម្រួល និងសហការជាមួយក្រុមការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស របស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីផ្សព្វផ្សាយអំពីផែនការក្នុងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស តាមរយៈប្រព័ន្ធផ្សព្វផ្សាយ វិទ្យុ ទូរទស្សន៍ សារព័ត៌មាន បង្កើតស្ប៊តអប់រំ ពិនិត្យកែលម្អ និងបង្កើតសារខ្លីតែមានន័យ
- រៀបចំកិច្ចប្រជុំរៀងរាល់ត្រីមាស និងធ្វើរបាយការណ៍អំពីសកម្មភាពការងារ ជូនថ្នាក់ដឹកនាំក្រសួង

- សម្របសម្រួល និងសហការជាមួយអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ និងដៃគូពាក់ព័ន្ធដទៃទៀត
- ប្រធានមានសិទ្ធិអញ្ជើញក្រុមការងារប្រជុំតាមការចាំបាច់។ ក្នុងករណីអវត្តមានអនុប្រធានដឹកនាំកិច្ចប្រជុំជំនួសតាមការប្រគល់សិទ្ធិពីប្រធាន។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

ខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អធិការនៃអធិការដ្ឋាន អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានក្នុងប្រការ១ ត្រូវអនុវត្តការកិច្ចតាមសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៦កើត ខែ អស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែ តុលា ឆ្នាំ២០២៣

**រដ្ឋមន្ត្រី**

នេត្រ ភក្ត្រា

កន្លែងទទួល:
- ថ្នាក់ដឹកនាំក្រសួងព័ត៌មាន
- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស **គ.ជ.ប.ជ**
- ក្រុមការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ក្រសួងអប់រំ យុវជន និងកីឡា
- ដូចក្នុងប្រការ៤
- ឯកសារ កាលប្បវត្តិ